ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អនុស្សរណៈអន្តរការិយាល័យ

**ជូនចំពោះ៖** **ការិយាល័យសហព្រះរាជអាជ្ញា**
**សហមេធាវីការពារក្តី អោ អាន**
**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤/២**

**ចម្លងជូន៖** **ចៅក្រម ប្រាក់ គឹមសាន (ប្រធាន)**
**ចៅក្រម ន័យ ថុល**
**ចៅក្រម ហួត វុទ្ធី**
**លោក លឹម ស៊ុយហុង (ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង)**
**ឯ.ឧ ក្រាញ់ តូនី (ប្រធានការិយាល័យរដ្ឋបាលស្តីទី)**
**លោក Knut ROSANDHAUG (អនុប្រធានការិយាល័យរដ្ឋបាល)**

**ពី៖** **ចៅក្រម Olivier BEAUVALLET និង**
**ចៅក្រម Kang Jin BAIK**

**កាលបរិច្ឆេទ៖** **ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០**

**កម្មវត្ថុ៖** **ការបញ្ជូនសំណុំរឿង ០០៤/២**

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ដែលជាសំណុំរឿងប្រឆាំងនឹង អោ អាន (“សេចក្តីពិចារណា”)។ ទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាដំណោះស្រាយពីរដាច់

ដោយឡែកពីគ្នា និងផ្ទុយគ្នាក្តី តែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់ មិនត្រូវបានបដិសេធដោយសម្លេងគាំទ្រភាគច្រើនលើសលប់នោះទេ។

២. ក្រោយពេលចេញសេចក្តីពិចារណា អង្គបុរេជំនុំជម្រះបានទទួល និងវិនិច្ឆ័យលើ "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង" ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ ("សំណើ")[1] និង "សំណើសុំការបញ្ជាក់ថា បានចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ" ដែលសហមេធាវីការពារក្តី អោ អាន ("សហមេធាវី") បានដាក់នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ("សំណើរបស់សហមេធាវី")[2] (រួមគ្នាហៅថា "សំណើ")។

៣. ចៅក្រមអន្តរជាតិកត់សម្គាល់ពីស្ថានភាពបច្ចុប្បន្ន ដែលថា ការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើស្ទើរតែមិនអាចកើតមាននាពេលអនាគត ហើយថា អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងស៊ីសង្វាក់គ្នាថា អង្គជំនុំជម្រះនឹងមិនទទួលយកសំណើច្រំដែលពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ ដែលបណ្តាលឲ្យអង្គជំនុំជម្រះមិនអាចធ្វើការសម្រេចជាឯកច្ឆ័ន្ទ ឬ ដែលមានការគាំទ្រដោយសម្លេងភាគច្រើនលើសលប់នោះឡើយ នៅពេលមានការសន្មតថា ចៅក្រមទាំងប្រាំរូបនៃអង្គជំនុំជម្រះនឹងប្រកាន់យកមតិយោបល់ពីមុនៗរបស់ខ្លួន និងធ្វើសេចក្តីសន្និដ្ឋានដូចពីមុន ដែលធ្វើឲ្យសំណើក្រោយៗក្លាយជាគ្មានន័យ និងអាចបង្កឲ្យមានវិវាទគ្មានទីបញ្ចប់[3]។ ចៅក្រមអន្តរជាតិបញ្ជាក់សាជាថ្មីថា វិធានស្តីពីសម្លេងភាគច្រើនលើសលប់ និងគោលជំហរជាក់ស្តែងដែលមានចែង

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/២") (អបជ ៦០) សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D359/25 និង D360/34 ("សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D359/25 និង D360/34)")។

[2] សំណុំរឿង ០០៤/២ (អបជ ៦០) សំណើសុំការបញ្ជាក់ថា បានចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ ឯកសារ D359/27 និង D360/36 ("សំណើរបស់សហមេធាវី (D359/27 និង D360/36)")។

[3] *សូមមើលឧទាហរណ៍* សំណុំរឿង ០០៤/២ (អបជ ០៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តាអាន ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D190/1/2 កថាខណ្ឌ ២០។

ក្នុងវិធានផ្ទៃក្នុង គឺជាលក្ខណៈពិសេសរបស់ អ.វ.ត.ក ដែលអាចបណ្តាលឲ្យអង្គជំនុំជម្រះមិនអាចឈានទៅមានសេចក្តីសម្រេចបានទៅលើបញ្ហាណាមួយ។

៤. ទាក់ទិននឹងស្ថានភាពបច្ចុប្បន្ន ព្រមទាំងវិធាន ២១(១) នៃវិធានផ្ទៃក្នុង ចៅក្រម Kang Jin BAIK និងចៅក្រម Olivier BEAUVALLET (“ចៅក្រមអន្តរជាតិ”) យល់ឃើញថាជាការចាំបាច់ ដែលត្រូវធ្វើការបញ្ជាក់ទៅលើអង្គច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធ ទាក់ទិននឹងការបញ្ជូនសំណុំរឿង ០០៤/២ និងផ្តល់មតិយោបល់របស់ខ្លួនទៅលើស្ថានភាពបច្ចុប្បន្ន តាមរយៈអនុស្សរណៈនេះ។

## II. ប្រវត្តិនីតិវិធី

៥. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ប្រឆាំងនឹង អោ អាន (“ដីកាសម្រេចលើកលែងចោទប្រកាន់”)[4] ចំណែកឯសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”)[5]។

៦. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាខ្មែរ[6]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ សហមេធាវីការពារក្តី អោ អាន (“សហមេធាវី”) បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាភាសាអង់គ្លេស[7] ហើយសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ជាភាសាអង់គ្លេស[8] (រួមគ្នាហៅថា “បណ្តឹងឧទ្ធរណ៍”)។

[4] សំណុំរឿង ០០៤/២ ដីកាសម្រេចលើកលែងចោទប្រកាន់ប្រឆាំងនឹង អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 ។

[5] សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360។

[6] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D360/8/1។

[7] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D360/5/1។

[8] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D359/3/1។

៧. នៅថ្ងៃទី១៩, ២០ និង ២១ ខែមិថុនា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានដំណើរការសវនាការក្នុងសំណុំរឿង ០០៤/២ ដើម្បីស្តាប់អំណះអំណាងរបស់ភាគីទាក់ទិននឹងបណ្តឹងឧទ្ធរណ៍។

៨. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ("សេចក្តីពិចារណា")[9]។ ក្រឡាបញ្ជីមួយរូបនៃអង្គជំនុំជម្រះបានដាក់ទម្រង់នៃការណែនាំស្តីពីការដាក់ និងការជូនដំណឹង ដោយណែនាំឱ្យអង្គភាពបណ្ណសារនៃការិយាល័យរដ្ឋបាល ("អង្គភាពបណ្ណសារ") ដាក់សេចក្តីពិចារណាជាសាធារណៈ និងជូនដំណឹងពីសេចក្តីពិចារណានេះទៅអង្គបុរេជំនុំជម្រះ ការិយាល័យសហចៅក្រមស៊ើបអង្កេត និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២[10]។

៩. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីមួយរូបនៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីក្នុងសំណុំរឿង ០០៤/២ តាមរយៈអ៊ីមែលថា "អង្គជំនុំជម្រះសាលាដំបូងបានដឹងពីសេចក្តីពិចារណាដែលអាចរកបានជាសាធារណៈ [...]។ ទោះជាយ៉ាងណាក្តី មកទល់នឹងពេលនេះ សេចក្តីពិចារណានេះមិនទាន់បានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ [...]"[11]។

១០. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីមួយរូបនៃអង្គបុរេជំនុំជម្រះបានណែនាំដល់អង្គភាពបណ្ណសារតាមរយៈអ៊ីមែល មិនឱ្យជូនដំណឹងអំពីសេចក្តីណែនាំទៅអង្គជំនុំជម្រះសាលាដំបូង និងរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារទេ[12]។ នៅថ្ងៃដដែលនោះ ក្រឡាបញ្ជីមួយរូបទៀតនៃអង្គជំនុំជម្រះបានដាក់ជូនទម្រង់បែបបទមួយ ដោយណែនាំដល់អង្គភាពបណ្ណសារឱ្យជូនដំណឹងអំពីសេចក្តីណែនាំដល់អង្គជំនុំជម្រះសាលាដំបូង[13]។

---

[9] សំណុំរឿង ០០៤/២ (អបជ ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33។

[10] ទម្រង់នៃការណែនាំស្តីពីការដាក់ និងការជូនដំណឹង ដាក់ដោយអ្នកស្រី Kristina O'YOUNG ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ (ឧបសម្ព័ន្ធ ១)។

[11] អ៊ីមែលពីលោក លឹម ស៊ុងហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ (ឧបសម្ព័ន្ធ ២)។

[12] អ៊ីមែលពីអ្នកស្រី Hyuree KIM ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ផ្ញើជូនចៅក្រមអន្តរជាតិ *ដោយបញ្ជូន* (១) សំណើរបស់ផ្នែកគ្រប់គ្រងតុលាការសុំការណែនាំចុងក្រោយតែមួយ ទាក់ទិននឹងការជូនដំណឹងអំពីសេចក្តីពិចារណា និង (២) ការណែនាំរបស់អ្នកស្រី រស់ បូផាណា ទៅផ្នែកគ្រប់គ្រងតុលាការ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ (ឧបសម្ព័ន្ធ ៣)។

[13] ការណែនាំពីការជូនដំណឹងសម្រាប់ការជូនដំណឹងពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទៅ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ (ឧបសម្ព័ន្ធ ៤)។

១១. នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះបានផ្ញើអនុស្សរណៈមួយច្បាប់ទៅប្រធានផ្នែកគ្រប់គ្រងតុលាការ ("CMS") ជាមួយចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ ព្រមទាំងចម្លងជូនប្រធានស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល ដោយលើកឡើងថា យោបល់ ឬសេចក្តីសម្រេចផ្ទាល់ខ្លួនរបស់ចៅក្រមម្នាក់ៗមិនមានប្រសិទ្ធភាពអនុវត្តឡើយ[14]។

១២. នៅថ្ងៃដដែលនោះ ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះបានផ្ញើអនុស្សរណៈអន្តរការិយាល័យមួយច្បាប់ជូនទៅប្រធានស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងប្រធានផ្នែកគ្រប់គ្រងតុលាការ ដោយចម្លងជូនប្រធាន និងចៅក្រមជាតិនៃអង្គជំនុំជម្រះ ដោយលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងទទួលយកសំណុំរឿង ០០៤/២ អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ហើយថា នាពេលនេះ ការិយាល័យរដ្ឋបាលទទួលបានណែនាំឲ្យជូនដំណឹងអំពីសេចក្តីណែនាំដល់អង្គជំនុំជម្រះសាលាដំបូង[15]។

១៣. នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ការិយាល័យរដ្ឋបាលបានផ្ញើអនុស្សរណៈអន្តរការិយាល័យមួយច្បាប់ជូនទៅចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ដោយចម្លងជូនចៅក្រមទាំងអស់នៃអង្គជំនុំជម្រះ ដោយស្នើសុំការបញ្ជាក់ជាអាជ្ញាបញ្ញា ស្តីពីការណែនាំពីរដែលផ្ទុយគ្នា ទាក់ទិននឹងការជូនដំណឹងអំពីសេចក្តីពិចារណាទៅអង្គជំនុំជម្រះសាលាដំបូងគួរយកមកអនុវត្ត ឬយ៉ាងណា ឬជាជម្រើសម្យ៉ាងទៀត សូមឲ្យមានការណែនាំមួយដែលអាចអនុវត្តបាន[16]។ មកទល់នឹងពេលនេះ សំណើនេះនៅរង់ចាំការសម្រេចនៅឡើយ។

១៤. នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង"[17]។

---

[14] អនុស្សរណៈចេញដោយចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ (ឧបសម្ព័ន្ធ ៥)។

[15] អនុស្សរណៈអន្តរការិយាល័យចេញដោយចៅក្រម Kang Jin BAIK ចៅក្រម Olivier BEAUVALLET ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ (ឧបសម្ព័ន្ធ ៦)។

[16] អនុស្សរណៈអន្តរការិយាល័យចេញដោយការិយាល័យរដ្ឋបាល ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ (ឧបសម្ព័ន្ធ ៧)។

[17] សំណុំរឿង ០០៤/២ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០។

១៥. នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើ ដោយស្នើសុំឲ្យអង្គបុរេជំនុំជម្រះចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីធានាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ០០៤/២ ដែលនៅសេសសល់ ត្រូវបានបញ្ជូនភ្លាមៗទៅអង្គជំនុំជម្រះសាលាដំបូង ដូចបានកំណត់អាណត្តិការងារនៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អ.វ.ត.ក") និង វិធានផ្ទៃក្នុង[18]។

១៦. នៅថ្ងៃដដែលនោះ ក្រឡាបញ្ជីមួយរូបនៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីក្នុងសំណុំរឿង ០០៤/២ តាមរយៈអ៊ីមែលថា "អង្គជំនុំជម្រះសាលាដំបូងបានដឹងពីសេចក្ដីពិចារណាដែលអាចរកបានជាសាធារណៈ [...]"។ ទោះជាយ៉ាងណាក្ដី "អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានទទួលការជូនដំណឹងអំពីសេចក្ដីពិចារណាជាផ្លូវការពីអង្គបុរេជំនុំជម្រះនៅឡើយទេ" ហើយ "សំណុំរឿងមិនទាន់បានបញ្ជូនមកទេ។ អង្គបុរេជំនុំជម្រះជាអ្នកដែលត្រូវចាប់ផ្ដើមដំណើរការសកម្មភាពទាំងពីរនេះ"[19]។

១៧. នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ សហមេធាវីបានដាក់ "ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង" ("ចម្លើយតបរបស់សហមេធាវី")[20] ដោយស្នើសុំឲ្យ អង្គបុរេជំនុំជម្រះបដិសេធសំណូមពរដែលបានស្នើសុំដោយសហព្រះរាជអាជ្ញាអន្តរជាតិ[21]។

[18] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D359/25 និង D360/34) កថាខណ្ឌ ១, ២៥, ២៩។

[19] អ៊ីមែលពីលោក លឹម ស៊ុងហុង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ (ឧបសម្ព័ន្ធ ៨)។

[20] សំណុំរឿង ០០៤/២ (អបជ ៦០) ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ដាក់នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ និងបានជូនដំណឹងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D359/26 និង D360/35 ("ចម្លើយតបរបស់សហមេធាវី (D359/26 និង D360/35)")។

[21] ចម្លើយតបរបស់សហមេធាវី (D359/26 និង D360/35) កថាខណ្ឌ ១, ២៩។

១៨. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ សហមេធាវីបានដាក់សំណើរបស់ខ្លួន ដោយស្នើសុំការបញ្ជាក់របស់អង្គបុរេជំនុំជម្រះថា បានចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ[22]។

១៩. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហមេធាវី[23]។

២០. នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបទៅនឹងសំណើរបស់សហមេធាវី[24]។

## III. ច្បាប់ជាធរមាន

២១. វិធាន ៧៧(១៤) ចែងថា៖

> សេចក្តីសម្រេចទាំងអស់ស្ថិតនៅក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងដែរត្រូវមានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រមទាំងនោះ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីដទៃទៀតដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតត្រូវបន្តកិច្ចនីតិវិធី ជាបន្ទាន់ស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

២២. វិធាន ៧៧(១៣) ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

---

[22] សំណើរបស់សហមេធាវី (D359/27 និង D360/36)។

[23] សំណុំរឿង ០០៤/២ (អបជ ៦០) ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ សុំឲ្យចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/28 និង D360/37 ("ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D359/28 និង D360/37)")។

[24] សំណុំរឿង ០០៤/២ (អបជ ៦០) ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ បានដាក់នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ និង ជូនដំណឹងនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/30 និង D360/39 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D359/30 និង D360/39)")។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម ៤(បួន) រូប យ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖

[…]

ខ) ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

២៣. វិធាន ៦៩ ចែងថា៖

1. នៅពេលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ ដូចមានចែងក្នុងវិធាន ៧៧។

2. នៅពេលដែលគ្មានបណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតត្រូវបិទសំណុំរឿងដោយមានបោះត្រាលើសំណុំរឿង និង៖

ក) ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីកំណត់កាលបរិច្ឆេទសវនាការ។

ខ) ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារក្រោយពីផុតរយៈពេលធ្វើបណ្តឹងឧទ្ធរណ៍។

២៤. ចៅក្រមអន្តរជាតិយល់ឃើញថា វិធានជាមូលដ្ឋានសម្រាប់ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មានចែងនៅក្នុងវិធាន ៦៩ និងវិធាន ៧៧(១៤)។ វិធាន ៧៧(១៤) ចែងថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីផ្សេងទៀត។ យោងតាមការអនុវត្តនាពេលកន្លងមក ចៅក្រមអន្តរជាតិពិចារណាឃើញថា វិធាន ៦៩ ចែងអំពីកាលៈទេសៈធម្មតាពាក់ព័ន្ធនឹងការបញ្ជូនសំណុំរឿង ដែល យោងតាម

វិធាននេះ ក្រោយពីបានជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយអនុលោមតាមវិធាន ៧៧(១៣) និង (១៤) ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត តាមធម្មតា នឹងបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ស្របតាមវិធាន ៦៩(២)(ក)។

## IV. ការពិភាក្សា

### ១. សេចក្តីផ្តើម

២៥. សហចៅក្រមអន្តរជាតិរម្លឹកថា នៅក្នុងសេចក្តីពិចារណារបស់ខ្លួន អង្គបុរេជំនុំជម្រះបានប្រកាសជាឯកច្ឆ័ន្ទថា ការដែលសហចៅក្រមស៊ើបអង្កេតចេញដំណោះស្រាយចំនួនពីរដាច់ដោយឡែកពីគ្នា គឺជាកិច្ចខុសច្បាប់[25]។ ទោះបីជាយ៉ាងនេះក្តី ចៅក្រមអង្គបុរេជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានផ្សេងគ្នាពាក់ព័ន្ធនឹងផលវិបាកនៃការធ្វើសេចក្តីសន្និដ្ឋានផ្សេងគ្នាបែបនេះ[26]។ ទោះបីជាចៅក្រមជាតិបានពិចារណាឃើញថា មានតែដីកាលើកលែងការចោទប្រកាន់ទេគួរត្រូវតម្កល់ទុកក៏ដោយ[27] ចៅក្រមអន្តរជាតិបានយល់ឃើញថា មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវចាត់ទុកជាបានការ ដោយសារដីកាលើកលែងការចោទប្រកាន់ បានធ្វើឡើង *ហួសដែនអំណាច* ត្រូវចាត់ទុកជាមោឃៈ និងពុំមានអានុភាពផ្លូវច្បាប់[28] ឬ បើមិនដូច្នោះទេ ទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់ ពុំត្រូវបានច្រានចោល ដោយសារពុំអាចរកសម្លេងភាគច្រើនលើសលប់បាន។

២៦. ដើម្បីធានាសច្ចភាពផ្លូវច្បាប់ តម្លាភាពនៃកិច្ចដំណើរការនីតិវិធី និងផលប្រយោជន៍នៃយុត្តិធម៌ អង្គបុរេជំនុំជម្រះបានបញ្ជាក់ជាឯកច្ឆ័ន្ទ និងដាក់លាក់នៅក្នុងផ្នែកសម្រេចសេចក្តីថា កិច្ចដំណើរការនីតិ

---

[25] សំណុំរឿង ០០៤/២ (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និងឯកសារ D360/33 កថាខណ្ឌ ១០១-១២៤។

[26] សំណុំរឿង ០០៤/២ (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និងឯកសារ D360/33 កថាខណ្ឌ ១២៤ កថាខណ្ឌ ១៧០-៣០២ កថាខណ្ឌ ៣០៤-៣២៩។

[27] សំណុំរឿង ០០៤/២ (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និងឯកសារ D360/33 កថាខណ្ឌ ២៨២ កថាខណ្ឌ ២៩៤ កថាខណ្ឌ ៣០២។

[28] សំណុំរឿង ០០៤/២ (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និងឯកសារ D360/33 កថាខណ្ឌ ៣២៦ កថាខណ្ឌ ៦៨៥។

វិធីនាពេលបន្តបន្ទាប់ក្រោយពេលចេញសេចក្តីពិចារណា ត្រូវគោរពតាមវិធាន ៧៧(១៣) និង (១៤)[29]។

## ២. អង្គបុរេជំនុំជម្រះបានបំពេញភារកិច្ចរបស់ខ្លួនរួចហើយ

២៧. អនុលោមតាមវិធាន ៧៧(១៤) ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបានដាក់ទម្រង់បែបបទឯកសារ និងការណែនាំអំពីការជូនដំណឹង ភ្លាមៗ ក្រោយពីបានចេញសេចក្តីពិចារណា ដោយបានបង្គាប់ឱ្យអង្គភាពបណ្ណសារ ដាក់សេចក្តីពិចារណាជាឯកសារសាធារណៈ និងជូនដំណឹងសេចក្តីពិចារណានេះទៅការិយាល័យសហចៅក្រមស៊ើបអង្កេត និងភាគីនៅក្នុងសំណុំរឿង ០០៤/២[30]។

២៨. ទោះបីជាយ៉ាងនេះក្តី ការិយាល័យសហចៅក្រមស៊ើបអង្កេតពុំបានចាត់វិធានការណាមួយមកទល់ពេលនេះនៅឡើយ។ ត្រង់ចំណុចនេះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតពុំមានបុគ្គលិកអន្តរជាតិចាប់តាំងពីខែសីហា ឆ្នាំ២០១៩ មក។

## ៣. អង្គបុរេជំនុំជម្រះបានចាត់វិធានការបន្ថែមនៅក្នុងដែនអំណាចរបស់ខ្លួន

២៩. យោងតាមវិធាន ២១(១) អង្គបុរេជំនុំជម្រះមានភារកិច្ច "ការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"។ ម្យ៉ាងវិញទៀត "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។ គ្មានសិទ្ធិណាមួយត្រូវបានការពារ ប្រសិនបើអង្គបុរេជំនុំជម្រះពុំធានាលទ្ធភាពឱ្យភាគីមានសិទ្ធិប្តឹងទៅចៅក្រមមានសមត្ថកិច្ច ពោលគឺ អង្គជំនុំជម្រះសាលាដំបូងទេនោះ។

---

[29] សំណុំរឿង ០០៤/២ (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និងឯកសារ D360/33 ទំព័រ ៦១ VII. ផ្នែកសេចក្តីសម្រេច។

[30] ទម្រង់បែបបទនៃការដាក់ឯកសារ និងការណែនាំអំពីសេចក្តីជូនដំណឹង ដាក់ដោយលោកស្រី Kristina O'YOUNG ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ (ឧបសម្ព័ន្ធ ១)។

៣០. អង្គបុរេជំនុំជម្រះបំពេញមុខងារដូចគ្នានេះនៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក មិនខុសពីសភាស៊ើបសួរកម្ពុជានោះទេ[31]។ លើសពីនេះ មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រង់កថាខណ្ឌ ៣ ចែងថា សភាស៊ើបសួរត្រូវបិទកិច្ចស៊ើបសួរដោយចេញដីកាដំណោះស្រាយ។ បញ្ញត្តិនៃមាត្រា ២៤៧ ដល់ មាត្រា ២៥០ នៃក្រមដដែលនេះ ស្តីពីដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ត្រូវយកមកអនុវត្តចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សភាស៊ើបសួរ។ មាត្រា ២៥០ កំណត់ថា នៅពេលចៅក្រមស៊ើបសួរសម្រេចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរត្រូវប្តឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះភ្លាមទៅប្រធានតុលាការ ដើម្បីកំណត់ពេលជំនុំជម្រះ។

៣១. ដោយហេតុថា ការិយាល័យសហចៅក្រមស៊ើបអង្កេតពុំមានបុគ្គលិក ដោយយល់ឃើញថា អង្គបុរេជំនុំជម្រះមានអំណាចស៊ើបអង្កេតរួម ដើម្បីឲ្យដំណើរការតុលាការប្រព្រឹត្តទៅដោយរលូន និងដើម្បីធានាសិទ្ធិរបស់ភាគី ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបានចាត់វិធានការបន្ថែម ដើម្បីកុំឲ្យកើតមានស្ថានភាពដែលមិនអាចអនុវត្តសាលដីការបស់ខ្លួនបាន ហើយធ្វើឲ្យរឿងក្តីនេះស្ថិតនៅក្នុងស្ថានភាពពុំច្បាស់លាស់គ្មានទីបញ្ចប់។

៣២. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបានដាក់ទម្រង់បែបបទមួយ បង្គាប់ឲ្យអង្គភាពបណ្ណសារជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៤/២[32]។

៣៣. ដោយពិនិត្យឃើញថា សេចក្តីពិចារណាមានចំណុចអាចអនុវត្តបាន និងកិច្ចដូចបានលើកឡើងខាងលើ ដែលអង្គបុរេជំនុំជម្រះបានធ្វើឡើង ចៅក្រមអន្តរជាតិប្រកាសថា អង្គបុរេជំនុំជម្រះបានចាត់គ្រប់វិធានការដែលមានជាធរមាន ហើយនឹងវិធានការបន្ថែម ដើម្បីឲ្យសេចក្តីពិចារណានេះមានអានុភាពអនុវត្ត។

---

[31] សំណុំរឿង ០០៤/២ (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៩ ឯកសារ D359/24 និងឯកសារ D360/33 កថាខណ្ឌ ៤៤។

[32] *សូមមើល* ការណែនាំអំពីសេចក្តីជូនដំណឹងសម្រាប់ការជូនដំណឹងអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទៅកាន់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ (ឧបសម្ព័ន្ធ ៤)។ ទោះបីជាយ៉ាងនេះក្តី ពុំមានន័យថា អង្គបុរេជំនុំជម្រះឯកភាពជាមួយនឹងការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងថា អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលការជូនដំណឹងអំពីសេចក្តីពិចារណាពីអង្គបុរេជំនុំជម្រះតាមរយៈផ្នែកគ្រប់គ្រងតុលាការ ទើបអាចទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងបាន។

## ៤. ស្ថានភាពបច្ចុប្បន្ន

៣៤. អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណានៅក្នុងរឿងក្តីបច្ចុប្បន្ននេះ និងបានចាត់វិធានការតម្រូវរួចអស់ហើយដើម្បីជូនដំណឹងអំពីសេចក្តីពិចារណានេះឲ្យបានសមស្រប។ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពុំបានបន្សល់នូវភាពស្រពិចស្រពិល ឬភាពពុំប្រាកដប្រជានោះឡើយចំពោះអត្ថិភាពនៃដីកាដំណោះស្រាយចំនួនពីរផ្ទុយគ្នា និងដោយឡែកពីគ្នា បើទោះជាករណីនេះពុំធ្លាប់មានពីមុនមកក៏ដោយ។

៣៥. ចៅក្រមអន្តរជាតិរម្លឹកថា អង្គបុរេជំនុំជម្រះពុំអាចរកសម្លេងភាគច្រើនលើសលប់ដើម្បីច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយគូសបញ្ជាក់ថា យោងតាមការយល់ឃើញរបស់ចៅក្រមអន្តរជាតិ ដីកាលើកលែងការចោទប្រកាន់ ធ្វើឡើង*ហួសដែនអំណាច* ត្រូវចាត់ទុកជាមោឃៈ និងពុំមានអានុភាពផ្លូវច្បាប់។ អាស្រ័យហេតុនេះ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ ដែលបានប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង មានអានុភាពអនុវត្ត ហើយសំណុំរឿង ០០៤/២ ពុំត្រូវដាក់បញ្ចូលក្នុងបណ្ណសារនោះឡើយ។

៣៦. ជាសេចក្តីសន្និដ្ឋាន អង្គបុរេជំនុំជម្រះបានចាត់គ្រប់វិធានការរដ្ឋបាលទាំងអស់ក្នុងការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង រួមទាំង បានដាក់ទម្រង់បែបបទឯកសារ និងការណែនាំអំពីការជូនដំណឹងកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ និងនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។ អាស្រ័យហេតុនេះ នាពេលនេះ គឺអាស្រ័យលើអង្គជំនុំជម្រះសាលាដំបូងជាអ្នកពិនិត្យលើរឿងក្តីមួយនេះ ដែលអង្គបុរេជំនុំជម្រះបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងរួចហើយ បើទោះជាមានកិច្ចការរដ្ឋបាលខ្លះពាក់ព័ន្ធនឹងការបញ្ជូនសំណុំរឿងនេះ។

៣៧. ចំណុចចុងក្រោយ ចៅក្រមអន្តរជាតិរម្លឹកថា តាមរយៈអនុស្សរណៈចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០[33] ចៅក្រមអន្តរជាតិបានផ្តល់ការបញ្ជាក់តាមសិទ្ធិអំណាចរបស់ខ្លួនរួចថាតើ សេចក្តីណែនាំណាមួយពាក់ព័ន្ធនឹងការជូនដំណឹងអំពីសេចក្តីពិចារណា មានសុពលភាពអនុវត្ត ហើយនឹងការណែនាំដែលមានអានុភាព ក្នុងការបញ្ជូនសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង។ ប្រសិនបើការិយាល័យរដ្ឋបាលនៅតែមិនចាត់វិធានការរដ្ឋបាល ដោយគ្មានមូលដ្ឋានច្បាប់ ភាគីពាក់ព័ន្ធនឹង

---

[33] អនុស្សរណៈអន្តរការិយាល័យ ចេញដោយចៅក្រម Kang Jin BAIK និងចៅក្រម Olivier BEAUVALLET ដែលជាចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ (ឧបសម្ព័ន្ធ ៦)។

កិច្ចដំណើរការនីតិវិធី ដូចមានចែងនៅក្នុងវិធាន ៦៩(២)(ក) អាចនឹងពិចារណាបង្កើតសមាសភាពការិយាល័យសហចៅក្រមស៊ើបអង្កេតឡើងវិញ។